ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤១២

ចុះថ្ងៃទី ១៦-១០-២០០០

សាលដីកា

លេខ : ១០២

ចុះថ្ងៃទី១៩ខែកក្កដាឆ្នាំ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២- លោក ស៊ុន ទឹម ជាចៅក្រម

៣- លោក ប្រាក់ គឹមសាន ជាចៅក្រម

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី យុគ សុគន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

លោក ថេង ស៊ុន ចៅក្រមរបាយការណ៍ "អវត្តមាន"

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៥៩ "ច" ចុះថ្ងៃទី១១-៩-២០០០ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ២៦០ ចុះថ្ងៃទី ២៥-៤-២០០០ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អន ចេវ ភេទ ប្រុស អាយុ ៣៧ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅ ភូមិព្រែកខ្មែរ ឃុំស្វាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

ឈ្មោះ អន ណាត ភេទ ស្រី អាយុ ៤០ ឆ្នាំ មុខរបរ ធ្វើស្រែ ទីលំនៅ-ភូមិលេខ១ ឃុំត្រើយស្លា ស្រុកស្អាង ខេត្ត កណ្តាល ។

ឈ្មោះ អន រិត ភេទ ប្រុស អាយុ ២២ ឆ្នាំ មុខរបរ ធ្វើស្រែ ទីលំនៅភូមិព្រែកសំរោង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

និង ចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ជុន ស៊ឹម ភេទប្រុស ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅ ភូមិដីថ្នល់ ឃុំស្វាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

កម្មវត្ថុបណ្តឹង :ប្តឹងទាមទារដីកេរ្តិ៍របស់ម្តាយនិងសុំបដិសេធកិច្ចសន្យាលក់ទិញ

តាមបណ្ដឹងសាទុក្ខលេខ៣៧៣ចុះថ្ងៃទី១៣_៩_២០០០ របស់លោក អន ចេវ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៩៩ "ច" ចុះថ្ងៃទី ១១_៨_២០០០ របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បាន ឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤១២ ចុះថ្ងៃទី ១៦_១០_២០០០ របស់ តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៥_៧_៩៥ របស់ឈ្មោះ អន ចេវ ប្ដឹងពីឈ្មោះ ផុន ស្រី សុំសិទ្ធិគ្រប់គ្រងដី និង សុំបដិសេធកិច្ចសន្យាលក់_ទិញចុះថ្ងៃទី ២៣_៧_៩៣ ដោយហេតុថាដីលំនៅដ្ឋាននេះជាកម្មសិទ្ធិរបស់ម្ដាយខ្លួនឈ្មោះ តាំង សុខ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ផ៧_១២៤២ ចុះថ្ងៃទី៧_៤_៩៣ ។ នៅឆ្នាំ ១៩៨៨ ម្ដាយខ្លួន និង ខ្លួនបានឯកភាពជួលដីនេះទៅអោយឈ្មោះ ផុន ស្រី ធ្វើរោង_ម៉ាស៊ីនកិនស្រូវ ។ នៅ ឆ្នាំ ១៩៩៣ ម្ដាយខ្លួនបានស្លាប់ ប្អូនស្រីខ្លួនឈ្មោះ អន មុំ ហ៊ានយកដីនេះទៅលក់អោយឈ្មោះ ផុន ស្រី ចំនួន ៧ជីមាស ប្អូនស្រីខ្លួនទទួលបានមាសត្រឹមតែ ២ជី កន្លះប៉ុណ្ណោះ នៅសល់ ២ជី ៥ហ៊ុនទៀត មិនទាន់អោយរហូតដល់សព្វថ្ងៃ ។

បាន ឃើញសាលក្រមលេខ ៥២ "ភ" ចុះថ្ងៃទី១៤_១២_៩៩ របស់ តុលាការខេត្ត កណ្ដាល ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :_

១_ទទួលស្គាល់ថាដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខផ៧_១២៤២ មានទីតាំងស្ថិតនៅភូមិព្រែកខ្មែរ ឃុំស្វាយភ្នំ ស្រុកស្អាង ខេត្តកណ្ដាល ជាបេតិកភ័ណ្ឌរបស់សពលោក_យាយ តាំង សុខ ដែលត្រូវបន្តអោយទៅទាយាទឈ្មោះ អន ណាត , ឈ្មោះ អន ចេវ ឈ្មោះ អន រិត និង ឈ្មោះ អន មុំ ។

២_ ចាត់ទុកជាមោឃៈនូវកិច្ចសន្យា ចុះថ្ងៃទី ២៣_៧_៩៣ រវាងឈ្មោះ _ អន មុំ និង ឈ្មោះ ផុន ស្រី ។

៣_ បង្គាប់អោយឈ្មោះ ផុន ស្រី បញ្ឈប់នូវសកម្មភាពប្រើប្រាស់លើដីដែលបានសំរេច ត្រង់ចំណុចទី១ ។

៤_ បង្គាប់អោយនាង អន មុំ សង មាសចំនួន ៤ជី ៥ ហ៊ុន "មាសទឹក៩៧" និង ការប្រាក់ ៥ភាគរយក្នុងមួយឆ្នាំ គិតពីថ្ងៃទី ២៣_៧_៩៣ រហូតដល់ថ្ងៃទូទាត់រួចទៅអោយឈ្មោះ ផុន ស្រី នាពេលសាលក្រមស្ថាពរ ។ ករណីរឹងទទឹងត្រូវអនុវត្តតាមច្បាប់ ស្ដីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥_ រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០រ.០០ ដែលដើមចោទបានបង់រួចហើយ ហើយអោយចុងចម្លើយ សងទៅដើមចោទវិញ ។

៦_ បង្គាប់អោយនាង អន មុំ បង់ពន្ធសមាមាត្រតាមអត្រា ១ភាគរយលើប្រាក់សំណង និង ការប្រាក់ ដែលឈ្មោះនេះត្រូវសងទៅអោយឈ្មោះ ផុន ស្រី ។

៧_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹង[illegible]
[illegible] ។

មិនសុខចិត្តនឹងសាលក្រមនេះ ឈ្មោះ ផុន ស្រី បានប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ០៥ ចុះថ្ងៃទី ១៧-០១-២០០០ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៩៩ "ច" ចុះថ្ងៃទី ១១-៩-២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ:-

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧-០១-២០០០ របស់ឈ្មោះ ផុន ស្រី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៥២ "ក" ចុះថ្ងៃទី១៤-១២-៩៩ របស់ តុលាការខេត្តកណ្តាលចោលជាអសារបង់ ។

៣- ប្រគល់ដីទំនាស់ស្ថិតនៅភូមិព្រែកខ្មែរ ឃុំស្វាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់ ដីធ្លីលេខ ដើ៧-១២៤២ ចុះថ្ងៃទី២៨-៩-៩២ អោយទៅឈ្មោះ ផុន ស្រី កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤- អោយឈ្មោះ ផុន ស្រី សងប្រាក់ថ្លៃទិញដីចំនួនពីរជី ៥ហ៊ុន "២,៥ជី" បន្ថែមទៀតអោយទៅឈ្មោះ អន ម៉ី ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥- ទុកសិទ្ធិអោយឈ្មោះ អន ណាត, អន ចេវ, និង អន រិត ប្តឹងទាមទារចំណែកមរតកពីឈ្មោះ អន មុំ រិញ ។

៦- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រ,០០ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហឹង ២.៥៥០រ,០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ,០០ - ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ៥.០០០រ,០០ និង លើអាជ្ញាធរតុលាការ ៥.០០០រ,០០ សរុប ចំនួន ១៣.០០០រ,០០ និង បង្គាប់អោយដើមចោទបង់ពន្ធសមាមាត្រ១ភាគរយលើថ្លៃដីទំនាស់ ។

៧- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ឈ្មោះ ផុន ស្រី ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់ឈ្មោះ អន ចេវ ចុះថ្ងៃទី ១៨-១០-២០០០ ។

បានឃើញសារណាតបរបស់ឈ្មោះ ផុន ស្រី ចុះថ្ងៃទី ៦-១២-២០០០ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :- សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អន ចេវ ដែលបានឆ្លើយនាពេលសវនាការថាៈ- ពេលម្តាយខ្លួននៅរស់គាត់ជួលអោយគេធ្វើរោងម៉ាស៊ីនកិនស្រូវរហូតដល់ឆ្នាំ ១៩៨២ ។ បណ្ណកម្មសិទ្ធិម្តាយខ្លួនធ្វើនៅឆ្នាំ ៨២ ។ ឆ្នាំ ៨៥ ខ្លួនដាំដើមចេក ស្រាប់ឈ្មោះ ផុន ស្រី យកកំលាំងមកកាប់ចោលហើយនិយាយថាដីនេះគាត់ទិញពីប្អូនខ្លួន ទើបខ្លួនដឹងថាដីនេះប្អូនខ្លួនលួចលក់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អន ណាត ដែលបានឆ្លើយនាពេលសវនាការថាៈ ខ្លួនស៊ីប្តឹងបដិសេធអ្នកលក់ និង អ្នកទិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អន រិត ដែលបានឆ្លើយនាពេលសវនាការថាៈ ខ្លួនក៏ដូចបងខ្លួនដែរ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ផុន ស្រី ដែលឆ្លើយនៅពេលសវនាការថា ៈ- ពេលនៅរស់យាយតាំង សុខ ធ្លាប់តិតជាមួយខ្លួន និង អន មុំ ថាចង់លក់ដី តែពេលលក់ពិតប្រាកដ យាយសុខ ស្លាប់ហើយ ។

ការនិយាយថ្លៃតីបាននិយាយជាមួយអន ណាត ទៀតផង ។

ដីនេះខ្លួនកាន់កាប់តាំងពីធ្វើកិច្ចសន្យារហូតមកដល់បច្ចុប្បន្ន ។

លោក ប៉ិច រិច្ចកា មេធាវីដើមចោទសន្និដ្ឋានថាៈ- ដីដែលអន មុំ លក់ជាដីសហកម្មសិទ្ធិ ។ ឈ្មោះ អន មុំ លក់ដោយគ្មានការយល់ព្រមពីបងប្អូន ហើយនៅជាអនីតិជន " អាយុប្រហែល១០ឆ្នាំ " ។

កិច្ចសន្យានេះមានតែស្នាមមេដៃអ្នកលក់ និង អ្នកទិញប៉ុណ្ណោះ គ្មានការបញ្ជាក់ពីរដ្ឋអំណាចទេ ។

- កិច្ចសន្យានេះជាកិច្ចសន្យាអវិគាត
- អ្នកលក់ជាអនីតិជន
- គ្មានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់ ហើយ អន មុំ ក៏បានសារភាពថាមិនបានប្រាប់បងដែរ ។
- កិច្ចសន្យានេះមិនទាន់ផុតអាជ្ញាយុកាលទេ ព្រោះកិច្ចសន្យាមិនទាន់បានបញ្ចប់ ដោយការប្រគល់លុយមិនទាន់គ្រប់ ។

ខ្លួនសុំតុលាការមេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-- --

- ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសារទុក្ខលេខ ៣៧៣ ចុះថ្ងៃទី១៣-៩-២០០០ របស់លោក-អន ចេវ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់នេះអោយទៅចុងចម្លើយដោយសំអាងលើកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី ២៣-៧-៩៣ ហើយថាដើមចោទបានដឹងពីការលក់-ទិញនេះ ហើយដោយពុំប្តឹងតវ៉ាធ្វើអោយដើមចោទផុតអាជ្ញាយុកាលពុំអាចប្តឹងបានទៀត នោះជាការពុំត្រឹមត្រូវទេ ពីព្រោះដីទំនាស់នេះជាដីដែលមានបណ្ណកម្មសិទ្ធិជាទ្រព្យអវិភាគ ហើយការលក់-ទិញនេះពុំទាន់បានអនុវត្តជាស្ថាពរនៅឡើយដែលពាំងអោយដើមចោទក្នុងនាមជាតតីយជនមានសិទ្ធិប្តឹងតវ៉ាបានតាមមាត្រា ១៧៩ ,១៨០ និង ១៨២ នៃ ច្បាប់ភូមិបាល និង មាត្រា ៤០ និង ៤១ នៃក្រឹត្យ-ច្បាប់លេខ ៣៨ក្រ-ច ចុះថ្ងៃ-ទី២៨-១០-៨៨ ។

- យល់ឃើញថា ការលក់-ទិញ ដីទំនាស់រវាងចុងចម្លើយ និង ឈ្មោះ អន មុំ នៅថ្ងៃទី ២៣-៧-៩៣ ពុំមានភស្តុតាងណាថាឈ្មោះអន ចេវ , អន ណាត និង - ឈ្មោះ អន រិត បានយល់ព្រមទេ ហើយនៅពេលលក់ដីទំនាស់នេះថ្ងៃទី ២៣-៧-៩៣ ឈ្មោះ អន មុំ ទើបតែមានអាយុ ១៧ ឆ្នាំទេ ដែលតាមមាត្រា ១៥ នៃ ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ-ច ចុះថ្ងៃទី ២៨-១០-៨៨ មិនអាចយកជាការបានឡើយ ។

- យល់ឃើញថា សាលដីការឧទ្ធរណ៍លេខ ៩៩ "ច" ចុះថ្ងៃទី ១១-៩-២០០០ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគតិ

១-ទទួលបណ្តឹងសារទុក្ខលេខ ៣៧៣ ចុះថ្ងៃទី ១៣-៩-២០០០ របស់លោក អន ចេវ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការឧទ្ធរណ៍លេខ ៩៩ "ច" ចុះថ្ងៃទី១១-៩-២០០០ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

-- --

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤១២ ចុះថ្ងៃទី ១៦_១០_២០០០ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក អន ចេវ បានបង់ទុកនៅតុលាការកំពូល ចំនួន ១៨.០០០៛០០ គឺ :_

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៨.០០០៛០០ ហើយតម្រូវអោយលោក ផុន ស្រ៊ី សងប្រាក់ចំនួន ១៩.០០០៛០០ នេះ ទៅលោក អន ចេវ វិញ ។

៥_ សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ១៩_ ខែ កក្កដា ឆ្នាំ ២០០១ ។